

# Prof. OUY Vanthon

# សាស្ត្រាចារ្យ អ៊ុយវ៉ាន់ថុន/ អ៊ុយវន្តថុន

(1937-2021)

*ដោយ*

*បណ្ឌិតសភាចារ្យឃីងហុកឌី*

# ជីវប្រវត្តិសង្ខេប

*អ៊ុយវ៉ាន់ថុនកើតនៅក្នុងទីរួមខេត្ត សៀមរាប នាថ្ងៃទី២មករា១៩៣៧។ បិតាលោកជាសហគ្រិន។*

*កុមារ វ៉ាន់ថុន រៀននៅសាលាបឋមសិក្សាក្នុងទីរួមខេត្តសៀមរាប រហូតដល់ប្រឡងជាប់វិញ្ញាបនបត្របឋមសិក្សាបានទៅសិក្សានៅវិទ្យាល័យព្រះមុនីវង្សក្នុងទីរួមខេត្តបាត់ដំបង ដោយបានទទួលអាហារូបករណ៍គឺកន្លែងសំណាក់នៅនិងបានអាហារបរិភោគ រហូតដល់បានប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាភាគទី១។ នៅសម័យនោះវិទ្យាល័យព្រះមុនីវង្សមិនទាន់មានថ្នាក់ទីបញ្ចប់ទេ។ យុវជនវ៉ាន់ថុន បានទទួលអាហារូបករណ៍រដ្ឋបន្តមករៀននៅវិទ្យាល័យព្រះស៊ីសុវត្ថិក្នុងក្រុងភ្នំពេញ រហូតដល់បាន ប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាភាគទី២* (Bac II) *។ បន្ទាប់ពីបានទទួលសញ្ញាបត្រ ដោយជោគជ័យ យុវជន វ៉ាន់ថុនបានទទួលអាហារូបករណ៍រដ្ឋាភិបាលបារាំងឲ្យមកបន្តការសិក្សានៅឧត្តមសិក្សាប្រទេសបារាំងផ្នែកគណិតសាស្ត្រ។*

*បន្ទាប់ពីរៀនចប់នៅប្រទេសបារាំង ដោលោកយបានទទួលបរិញ្ញាបត្រគណិតសាស្ត្រពីសាកលវិទ្យាល័យ «បរដូ»* (Université de Bordeaux) *លោកអ៊ុយវ៉ាន់ថុន ក៏បាន*

ត្រឡប់ចូលប្រទេសកម្ពុជាវិញនាឆ្នាំ១៩៦១[1]។ ដំបូងលោកបានទទួលការតែងតាំងជានាយកវិទ្យាល័យព្រះយុគន្ធរនៅក្រុងភ្នំពេញ។ នាឆ្នាំ១៩៦៣ លោកបានទទួលការតែងតាំងជានាយកវិទ្យាស្ថានគរុកោសល្យ (Institut National Pédagogique - INP) នៅទីក្រុងភ្នំពេញ។

វេលារដូវផ្ការីកឆ្នាំ១៩៦៥, សាស្ត្រាចារ្យ អ៊ុយវ៉ាន់ថុន បានទទួលការតែងតាំងជានាយកគណៈមេប្រយោគប្រឡងសញ្ញាបត្រនៅខេត្តកំពង់ចាម។ នាពេលនោះ ព្រហ្មលិខិតនាំឲ្យលោកបានជួបកញ្ញា ម៉ាយូមីម៉ាន (Mayoumi Man) ដែលធ្វើឲ្យលោកមានក្ដីប្រតិពទ្ធ យ៉ាងខ្លាំងហើយបានរៀបអាពាហ៍ពិពាហ៍នៅថ្ងៃ៣១តុលា១៩៦៥។

ឆ្នាំ១៩៦៦ លោកបានបុត្រ១ ឈ្មោះ វ៉ាន់ថូនី (Vanthony) ហើយ១៨ខែក្រោយមកលោកបានបុត្រ១ទៀតឈ្មោះវ៉ាន់ថូណា (Vanthona) ដែលបានទទួលអនិច្ចកម្មដ៏ខ្លោចផ្សាដោយគ្រោះថ្នាក់ទោចក្រយានយន្តនៅឆ្នាំ២០០២។

នាឆ្នាំ១៩៦៧ លោកបានទទួលការតែងតាំងជាព្រឹទ្ធបុរសវិទ្យាស្ថានបច្ចេកទេសជាន់ខ្ពស់ «មិត្តភាពខ្មែរសូវៀត»(ITSAKS)។

---

[1] សូមអានសៀវភៅ*Les élites khmères*, Phnom Penh, Coll. Culture et Civilisation khmères n°8, 1965, p.131.



SCIENCES :

CHARLES LY SORARITH (1951) (1)
Licencié es Sciences de la Faculté des Sciences de Montpellier.

PONG KIM KOAN (1958)
Licencié es Sciences naturelles de la Faculté des Sciences de Montpellier.

IN RON (1959)
Licencié d'enseignement es Sciences ( Mathématiques) de la Faculté des Sciences de Montpellier.

Mme DYPHON née TAN PAULINE (1959)
Licenciée es Sciences naturelles de la Faculté des Sciences de Paris.

PHU SY UY (1961)
Docteur es Sciences du 3ème cycle de la Faculté des Sciences de Paris

IM SAROEUN (1961)
Licencié es Sciences, Diplômé de l'Ecole Nationale Supérieure des Ingénieurs de l'Institut Polytechniqu de Grenoble (Radio -électricité).

OUY VANTHON (1961)
Licencié es Sciences de la Faculté des Sciences de Bordeaux.

(1) Date de leur retour au Cambodge.

*នៅក្នុងស្ថានភាពតឹងតែងក្នុងសង្គ្រាម នាខែវិច្ឆកា១៩៧០ លោកសាស្ត្រាចារ្យបានបុត្រី១នាម សូវីកា* (Sovira) *លោកបានទទួលតំណែងជាអនុរដ្ឋលេខាធិការក្រសួងអប់រំជាតិ* (INNOTECH) *ក្នុងរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ។ តួនាទីនេះបានតែងតាំងពី១៩៧១ដល់១៩៧២ជាជំនួយការលោកលន់ណល់ ប្រធានាធិបតីសាធារណរដ្ឋខ្មែរ។*

*នាឆ្នាំ១៩៧២សាស្ត្រាចារ្យអ៊ុយវ៉ាន់ថុនបានទទួលការអញ្ជើញជាអ្នកជំនាញការក្នុងអង្គការ* SEAMEO (INNOTECH)[2] *វៀតណាម។ បន្ទាប់មកលោកបានទទួលតំណែងជានាយករងរហូតដល់ឆ្នាំ១៩៧៥ដែលមានស្នាក់ការនៅព្រៃនគរ។ មុនថ្ងៃធ្លាក់ព្រៃនគរនាថ្ងៃ៣០មេសា១៩៧៥, លោកអ៊ុយវ៉ាន់ថុនព្រមទាំងគ្រួសារបានចេញដំណើរទៅប្រទេសកាណាដាដោយឆ្លងកាត់១រយៈតាមប្រទេសបារាំង។*

*គ្រួសារលោកអ៊ុយវ៉ាន់ថុនតាំងទីរស់នៅក្រុងម៉ុងរេអាល ហើយសាស្ត្រាចារ្យវ៉ាន់ថុនបានបង្រៀនវិទ្យាសាស្ត្រនៅម៉ានីវ៉ាគី* (Maniwaki)*។ នាឆ្នាំ១៩៧៦លោកវ៉ាន់ថុនបានជាប់ឆ្នោតជាប្រធានសហគមខ្មែរនៅកាណាដា។*

*អស់ចិត្តក្នុងការបង្រៀននិងការអប់រំជាតិនៅកេបិច*(Québec), *លោកអ៊ុយវ៉ាន់ថុនបែរទៅធ្វើជាសហគ្រិនវិញ។*

*បន្ទាប់ពីការបោះឆ្នោតនៅកម្ពុជានៅឆ្នាំ១៩៩៣, លោកអ៊ុយវ៉ាន់ថុននិងភរិយាត្រឡប់ទៅនៅមាតុភូមិវិញ។ ដោយលោកមានទស្សននិស្ស័យនិងចេតនារស់នៅក្នុងមាតុភូមិហើយចង់ធ្វើវិភាគទានដើម្បីវឌ្ឍនភាពរីកចម្រើននិងកសាងជាថ្មីឡើងវិញ ជាពិសេសលើវិស័យអប់រំ វិទ្យាសាស្ត្រនិងបច្ចេកទេស។*

*នាឆ្នាំ១៩៩៥,សាស្ត្រាចារ្យអ៊ុយវ៉ាន់ថុនត្រឡប់យកតំណែងចាស់លោកនៅវិទ្យាស្ថានបច្ចេកទេសកម្ពុជាជាប្រធានរហូតដល់ឆ្នាំ២០០០ជាឆ្នាំដែលលោកត្រូវចូលនិវត្តន៍។*

*លោកទទួលអនិច្ចកម្មនៅថ្ងៃ២៨ឧសភា២០២១ដោយរោគាពិធ*(*មហារីក*)*។*[3]

---

[2] *នេះជាអក្សរកាត់សម្គាល់អង្គារអប់រំបច្ចេកទេសអន្តរជាតិនៅអាស៊ីអគ្នេយ៍។ សូមមើលអាំងទែណែតតាមតំណនេះ៖* https://www.seameo-innotech.org/about-innotech/

[3] ជីវប្រវត្តិសង្ខេបនេះបានជំនួយពីគ្រួសារសាស្ត្រាចារ្យអ៊ុយវ៉ាន់ថុន ជាពិសេសពីលោកកឹកប៊ុនប៉ុង។

# ឧបសម្ព័ន្ធ



រូបថតនាឆ្នាំ១៩៦១នៅមុខគេហដ្ឋានគ្រួសារលោកអ៊ុយវ៉ាន់ថុន ក្នុងទីរួមខេត្តសៀមរាប។ ពីស្តាំទៅឆ្វេង គឺ អ៊ុយវ៉ាន់ដេត, បិតាលោក, លោកអ៊ុយវ៉ាន់ថុន, កញ្ញា អ៊ុយសុមាលី (ជាអនាគតភរិយាលោកវិស្វករកឹកប៊ុនប៉ុង), មាតាលោក, បងស្រីលោកនិងស្វាមី ព្រមទាំងក្មួយប្រុសស្រីលោក។ (រូបថតកម្មសិទ្ធិគ្រួសារសាស្ត្រាចារ្យ អ៊ុយវ៉ាន់ថុន)។

.



## ពីស្នេរដដែល

——★★——

- សៀវភៅគំហើញ ឬសំរស់ជីវិត (បោះលើកទី២អស់)
- សៀវភៅជំទង់ភាគស្នេហា និងភាគចំណេះ (បោះលើកទី២)
- សំនៅចុងក្រោយ (បណ្ណាគារខ្មែរមន)
- ហ្សង់ប៉ូលសាត្រ និងអាល់បែរកាមិស (អស់)

●

- គណិតសាស្ត្រថ្នាក់ទី ៨-៧-៦-៥-៤-៣ (ធ្វើជាមួយគណកម្មការបច្ចេកទេសខាងគណិតសាស្ត្រ នៃខេមរយានកម្មសិក្សា ដែលមានលោក អ៊ុយ វន្តថុន ជាប្រធាន)

●

ប្រុងបោះផ្សាយ :

- ជូននារីម្នាក់ (កំណាព្យ)
- ចិត្តសាស្ត្រសំរាយ (Psychologie pour tous)

លោកអ៊ុយវន្តថុន (អ៊ុយវ៉ាន់ថុន) ជាប្រធានគណៈកម្មការខេមរយានកម្មគណិតវិទ្យានៅសម័យសង្គមរាស្ត្រនិយម (ដូចមានសេចក្តីបញ្ជាក់នៅទំព័រដើមក្នុងស្នាដៃអក្សរសិល្ប៍ ឃុនស្រ៊ុនជាគ្រូគណិតវិទ្យានៅមធ្យមសិក្សាមានចំណងជើងថា«សំនៅចុងក្រោយ»ដែលជាអ្នកបានធ្វើការរួមជាមួយលោកវ៉ាន់ថុនក្នុងគណៈកម្មការខេមរយានកម្មគណិតវិទ្យា ។



រូបថតនាឆ្នាំ១៩៧០ ជាមួយសហសេវិកជាសាស្ត្រាចារ្យភាសាអង់គ្លេស។ សាស្ត្រាចារ្យអ៊ុយ វ៉ាន់ថុន ឈរនៅកណ្ដាលហើយរូបនៅឆ្វេងដៃទី៣គឺលោកគ្រូមាសចាន់ថន ហើយនៅស្ដាំដៃទី៣ គឺលោកគ្រូ ទ្រឿងមាលី (ជាសាស្ត្រាចារ្យភាសាអង់គ្លេសនៅវិទ្យាល័យខ្មែរអង់គ្លេសនៅភ្នំពេញ)។




*លោក* **អ៊ុយវ៉ាន់ថុន**

*ព្រឹទ្ធបុរសនៃវិជ្ជាស្ថានបច្ចេកទេសជាន់ខ្ពស់មិត្តភាពខ្មែរ -សូវៀត*




និស្សិតវិស្វករជំនាន់ទី១នៅវិជ្ជាស្ថានបច្ចេកទេសជាន់ខ្ពស់មិត្តភាពខ្មែរ-សូវៀត

(រូបថតកម្មសិទ្ធិលោកវិស្វករ ម៉ែនសុវណ្ណា)



រូបថត សាស្ត្រាចារ្យ អ៊ុយវ៉ាន់ថុនដែលបានតាំងក្នុង ឈាបនដ្ឋាន »Salon Funéraire Lajeunesse Fortin Cenac » នៅប្រទេស កាណាដា